- សិក្សាស្រាវជ្រាវលើប្រធានបទពាក់ព័ន្ធនឹងការគ្របដណ្តប់សុខភាពជាសកល តាមការចាំបាច់

ផ្នែកតាមដាន និងវាយតម្លៃ៖

- រៀបចំក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនទីបង្ហាញផ្លូវ
- អនុវត្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវ និងវាយតម្លៃពាក់កណ្តាលអាណត្តិ
- តាមដានវឌ្ឍនភាពនៃការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា និងការអនុវត្តកម្មវិធីជាតិជំនួយសង្គម របបសន្តិសុខសង្គម និងអន្តរាគមន៍ពាក់ព័ន្ធនឹងការគ្របដណ្តប់សុខភាពជាសកល
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវ ជូនគណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម និងរាជរដ្ឋាភិបាល

ផ្នែកសម្របសម្រួល៖

- រៀបចំ និងអនុវត្តផែនការអប់រំ ផ្សព្វផ្សាយ និងលើកកម្ពស់ចំណេះដឹងស្តីពីការគ្របដណ្តប់សុខភាពជាសកល
- សម្របសម្រួលការរៀបចំ និងអនុវត្តផែនការកសាងសមត្ថភាពដល់ស្ថាប័ន និងភាគីពាក់ព័ន្ធដើម្បីអនុវត្តគោលនយោបាយ និងអន្តរាគមន៍ដែលមានកំណត់ក្នុងផែនទីបង្ហាញផ្លូវ
- សម្របសម្រួលជាមួយដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធ រួមទាំងគាំទ្រផ្នែកគតិយុត្ត ក្នុងដំណើរនៃការអនុវត្តផែនទីបង្ហាញផ្លូវ
- រៀបចំផែនការអភិវឌ្ឍន៍លេខាធិការដ្ឋាន ផែនការសកម្មភាព ផែនការថវិកា និងអនុវត្តសកម្មភាពគាំទ្រការប្រព្រឹត្តទៅរបស់ អ.គ.ស.ស. និងលេខាធិការដ្ឋាន
- រៀបចំបូកសរុបរបាយការណ៍ការងារប្រចាំគ្រារបស់លេខាធិការដ្ឋាន។

**ប្រការ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសមាសភាពក្នុងប្រការ ១ និងប្រការ ៤ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ២ រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៤៥ សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ១០៧ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានតែងតាំងសមាសភាពនៃគណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តមសាស្ត្រាចារ្យ | **ឈាង រ៉ា** | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | ប្រធាន |
| ២- ឯកឧត្តម | **សាម្ញូ អូហ្សាណា** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | អនុប្រធាន |
| ៣- ឯកឧត្តម | **ជាម ហ៊ីម** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៤- ឯកឧត្តម | **សាន់ សាប់អ៊ី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធានអចិន្ត្រៃយ៍ |

| | | | |
|---|---|---|---|
| ៥- ឯកឧត្តម | **សួច សុភ័ណ្ឌា** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- ឯកឧត្តម | **មៀច សុផាន់ណា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៧- ឯកឧត្តមឧត្តមសេនីយ៍ឯក | **លី ភុសល** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៨- ឯកឧត្តម | **មាស គឹមហេង** | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩- ឯកឧត្តមបណ្ឌិត | **ផាន់ ផល្លា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១០- លោកជំទាវ | **ទេព ម៉ូរ៉ាមីន** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិកា |
| ១១- ឯកឧត្តម | **លេង ផាលី** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១២- ឯកឧត្តម | **ម៉ក់ ពេជ្ររិទ្ធ** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣- ឯកឧត្តម | **សេន សុវណ្ណា** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៤- ឯកឧត្តម | **សយ ភីរម្យ** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១៥- ឯកឧត្តម | **សុខ ម៉ិនថា** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៦- ឯកឧត្តម | **ម៉ិន ហ៊ាន** | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៧- ឯកឧត្តម | **ឈាន លាង** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៨- ឯកឧត្តម | **ព្រហ្ម សិទ្ធត្រា** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១៩- ឯកឧត្តម | **ខាយ ឃុនហេង** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២០- ឯកឧត្តម | **ហោ សារុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២១- លោកជំទាវ | **ម៉ាន ចិន្តា** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |
| ២២- ឯកឧត្តម | **ហ៊ុយ ហានសុខ** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៣- លោកជំទាវ | **នឹង ស៊ីមន** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិកា |
| ២៤- លោកជំទាវ | **មីន មាណាវី** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិកា |
| ២៥- លោកជំទាវ | **គឹម សេដ្ឋានី** | រដ្ឋលេខាធិការប្រចាំការក្រសួងអប់រំ យុវជន និងកីឡា | សមាជិកា |
| ២៦- លោកជំទាវ | **សុភ័ក្ត ថាវី** | រដ្ឋលេខាធិការក្រសួងអធិការកិច្ច | សមាជិកា |

| | | | |
|---|---|---|---|
| ២៧- លោកជំទាវ | **ឡូន ម៉ុនណា** | រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | សមាជិកា |
| ២៨- ឯកឧត្តម | **ម៉ា នរិទ្ធ** | អគ្គលេខាធិការរងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក។ |

**ប្រការ២ .-**

សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៥១ សសរ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការជាតិបរិស្ថាន និងសុខភាព និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៣ រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ កក្កដា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.....សហវ.....

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការតែងតាំងភ្នាក់ងារបើកផ្តល់
# សម្រាប់បើកផ្តល់ប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ ជូនមន្ត្រីរាជការ នៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ ០៦.នស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ នៃក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ១.**_

ប្រាក់បៀវត្សមន្ត្រីរាជការ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ របស់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺត្រូវបើកផ្តល់តាមរយៈភ្នាក់ងារបើកផ្តល់។

**ប្រការ២.**_

ត្រូវបានតែងតាំងភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស របស់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ ដូចខាងក្រោម ៖

១-លោក ឬ ខែម មុខងារជាប្រធានការិ.ផែនការ និងគណនេយ្យ ជាភ្នាក់ងារបើកផ្តល់ប្រចាំនៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ។

២-លោក សាន់ សាវុឌ្ឍ មុខងារជាអនុប្រធានការិ.ផែនការ និងគណនេយ្យ ជាភ្នាក់ងារបើកផ្តល់ជំនួសប្រចាំនៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ។

**ប្រការ៣.**_

លោក ឬ ខែម ជាភ្នាក់ងារបើកផ្តល់ និងលោក សាន់ សាវុឌ្ឍ ជាភ្នាក់ងារបើកផ្តល់ជំនួស ត្រូវបានអនុញ្ញាតឱ្យបើកគណនីប្រាក់បញ្ញើនៅអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីទទួលមូលនិធិ សម្រាប់យកទៅបើកប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ជូនមន្ត្រីរាជការ។

២/៣

**ប្រការ៤._**

បែបបទនៃការអនុវត្តបើកផ្តល់ប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ត្រូវបានកំណត់ដោយសេចក្តីណែនាំជាក្រោយ។

**ប្រការ៥._**

ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និងមូលនិធិដែលបានទទួលដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ។

**ប្រការ៦._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ នៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៥ កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-ក្រសួងអប់រំ យុវជន និងកីឡា
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៧
-រាជកិច្ច
-ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០៥៥៤.....សហវ.គស.គល

## សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពគណៈកម្មការជម្រះ និងលក់ទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់អង្គភាពប្រើប្រាស់ថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំង និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើសម្បត្តិរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធី នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើត និងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia



ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៦៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការប្រែក្លាយពីទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល ទៅជាទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការបង្កើត និងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសារាចរលេខ ០៧ សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ ស្ដីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- បានឃើញសារាចរលេខ ០០១ សហវ.សរ.អទច ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ ស្ដីពីការផ្ទេរសិទ្ធិកាន់កាប់និងប្រើប្រាស់លើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញប្រកាសលេខ ០០២ សហវ.ប្រក.អល ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២០ ស្ដីពីការវិធាន និងនីតិវិធីលម្អិតនៃការជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- បានឃើញប្រកាសលេខ ០០៧ សហវ.ប្រក ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ ស្ដីពីការកំណត់អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៨០៦ សហវ.ប្រក.អល ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីការបំពេញបន្ថែមអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្ដីសម្រេចលេខ ០០៣ សហវ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១ ស្ដីពីការកែសម្រួលសមាសភាពគណៈកម្មការជម្រះ និងលក់ទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់ថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការជម្រះ និងលក់ទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់ថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលសរសេរអក្សរកាត់ថា "**គ.ជ.ល.**" ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **មាស សុខសេនសាន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- លោកជំទាវ **លឹម ឈុនលី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- ឯកឧត្តម **ឯក ចន្ថា** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន កសហវ. | អនុប្រធានប្រចាំការ |
| ៥- ប្រធានអង្គភាពប្រើប្រាស់ពាក់ព័ន្ធ | | សមាជិក |
| ៦- លោកស្រី **សុខ សុរិយា** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន កសហវ. | សមាជិក |
| ៧- លោក **ទុំ ម៉ុងហេង** | ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក។ |

**ប្រការ២.-**

**គ.ជ.ល.** មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ធានាប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៃការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ សម្រាប់ជម្រះទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះ
- ពិនិត្យលើសំណើសុំជម្រះទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់ថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន
- ប្រមូលផ្តុំទ្រព្យសម្បត្តិរដ្ឋ (ចលនទ្រព្យ) ដែលត្រូវជម្រះតាមការចាំបាច់ ដើម្បីពិនិត្យគុណភាព និងស្ថានភាព នៃទ្រព្យសម្បត្តិរដ្ឋនោះ ដើម្បីលើកសំណើសុំគោលការណ៍ពិនិត្យ និងសម្រេច ឬផ្តល់ការណែនាំពីប្រធាន **គ.ជ.ល.** ឬរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែអចលនទ្រព្យត្រូវចុះពិនិត្យដល់ទីតាំងផ្ទាល់
- រៀបចំ និងដឹកនាំការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃសម្រាប់ការជម្រះទ្រព្យសម្បត្តិរដ្ឋដែលត្រូវជម្រះរបស់អង្គភាពប្រើប្រាស់ថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន
- ដំណើរការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃត្រូវប្រព្រឹត្តទៅនៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬតាមការកំណត់របស់ប្រធាន **គ.ជ.ល.**
- សិក្សា និងវាយតម្លៃទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវជម្រះដោយផ្អែកលើតម្លៃទីផ្សារជាក់ស្តែង និងត្រូវអនុលោមតាមនីតិវិធីជាធរមាន
- ពិនិត្យ និងសម្រេចជាគោលការណ៍ឱ្យដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ។ ក្នុងករណីចាំបាច់ **គ.ជ.ល.** ត្រូវផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីស្នើសុំការពិនិត្យ សម្រេច ឬផ្តល់ការណែនាំជាយថាហេតុ
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់ប្រធាន **គ.ជ.ល.**។

**ប្រការ៣.-**

**គ.ជ.ល.** ត្រូវបំពេញនីតិវិធី នៃការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ ដោយអនុលោមទៅតាមវិធាន និងនីតិវិធីដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៤.-**

**គ.ជ.ល.** មានលេខាធិការដ្ឋានមួយ ដើម្បីជួយសម្របសម្រួល និងគាំទ្រដល់ការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។ សមាសភាពលេខាធិការដ្ឋាន **គ.ជ.ល.** ត្រូវបានកែសម្រួលដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ឯក ចន្ថា** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន កសហវ. | ប្រធាន |
| ២- លោកស្រី **សូច សុរិយា** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន កសហវ. | អនុប្រធានប្រចាំការ |
| ៣- លោក **ទុំ ម៉ុងហេង** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- លោក **ផេង អ៊ី** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៥- លោក **ហ៊ីន ពិសិដ្ឋ** | ប្រធានការិយាល័យសម្ភារនិងទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៦- លោក **ស៊ី វាសនា** | អនុប្រធានការិយាល័យសម្ភារនិងទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៧- លោក **ខ៉ាម សុធារ៉ា** | អនុប្រធានការិយាល័យសម្ភារនិងទ្រព្យសម្បត្តិរដ្ឋ | សមាជិក។ |

**ប្រការ៥.-**

លេខាធិការដ្ឋាន **គ.ជ.ល.** មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ជានាកិច្ចដំណើរការប្រចាំថ្ងៃ និងរៀបចំកិច្ចប្រជុំរបស់ **គ.ជ.ល.**
- រៀបចំ និងបូកសរុបគម្រោងជម្រះបញ្ជីប្រចាំឆ្នាំរបស់អង្គភាពប្រើប្រាស់ពាក់ព័ន្ធ ដែលស្នើសុំជម្រះយ៉ាងយូរត្រឹមដំណាច់ត្រីមាសទី១ នៃឆ្នាំបន្ទាប់
- ពិនិត្យ និងផ្តល់យោបល់លើគម្រោងជម្រះបញ្ជីប្រចាំឆ្នាំជូនប្រធាន **គ.ជ.ល.** ពិនិត្យ និងសម្រេចយ៉ាងយូរត្រឹមដំណាច់ខែឧសភា នៃឆ្នាំបន្ទាប់
- ឆ្លើយតបជូនអង្គភាពប្រើប្រាស់ពាក់ព័ន្ធ ស្តីពីលទ្ធផល នៃការលើកសំណើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យ-សម្បត្តិរដ្ឋប្រចាំឆ្នាំយ៉ាងយូរត្រឹមដំណាច់ខែកក្កដា នៃឆ្នាំបន្ទាប់
- រៀបចំឯកសារដេញថ្លៃ និងចរចាពិគ្រោះថ្លៃ ផ្អែកតាមទម្រង់គំរូឯកសារពាក់ព័ន្ធជាធរមាន
- រៀបចំ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការប្រកាសដេញថ្លៃ និងចរចាពិគ្រោះថ្លៃ
- រៀបចំ និងផ្តល់ពាក្យស្នើសុំចូលរួមដេញថ្លៃ និងចរចាពិគ្រោះថ្លៃ
- ទទួលសំណើដេញថ្លៃ និងចរចាពិគ្រោះថ្លៃ ឬបកស្រាយបំភ្លឺចំពោះបេក្ខជនដែលមានសំណើពាក់ព័ន្ធនឹងការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ
- រៀបចំ និងគ្រប់គ្រងសំណើដេញថ្លៃ និងចរចាពិគ្រោះថ្លៃ រួមទាំងឯកសារពាក់ព័ន្ធដែលបានទទួល ប្រកបដោយភាពត្រឹមត្រូវ មុនពេលបើកសំណើដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ
- ចាត់ចែង និងរៀបចំទីកន្លែងសម្រាប់បើកដំណើដេញថ្លៃ និងចរចាពិគ្រោះថ្លៃ
- រៀបចំបើកសំណើដេញថ្លៃជាសាធារណៈ និងចរចាពិគ្រោះថ្លៃ ដោយមានការត្រួតពិនិត្យពី **គ.ជ.ល.**
- រៀបចំលិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យាដល់បេក្ខជនដេញថ្លៃ និងចរចាពិគ្រោះថ្លៃឈ្នះ និងចម្លងជូនបេក្ខជនដេញថ្លៃ ឬចរចាពិគ្រោះថ្លៃចាញ់ទាំងអស់
- រៀបចំសៀវភៅបន្ទុកស្តីពីការដេញថ្លៃ និងចរចាពិគ្រោះថ្លៃ
- រៀបចំកិច្ចសន្យាអនុវត្តសៀវភៅបន្ទុកស្តីពីការដេញថ្លៃ និងចរចាពិគ្រោះថ្លៃ
- រៀបចំលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ និងចរចាពិគ្រោះថ្លៃ
- រៀបចំលិខិតអះអាងប្រគល់ប្រាក់កក់ធានាការដេញថ្លៃ និងចរចាពិគ្រោះថ្លៃលក់ទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- រៀបចំកំណត់ហេតុរួមស្តីពីលទ្ធផល នៃការដេញថ្លៃ និងចរចាពិគ្រោះថ្លៃដោយមានសមាសភាពពីគ្រប់ភាគីពាក់ព័ន្ធ និងចុះហត្ថលេខារួមគ្នាលើកំណត់ហេតុនោះ
- លើកសំណើសុំគោលការណ៍ជម្រះទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់អង្គភាពប្រើប្រាស់ពាក់ព័ន្ធ ជូនប្រធាន **គ.ជ.ល.** ដើម្បីស្នើសុំការពិនិត្យ និងសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យ និងតាមដានអង្គភាពប្រើប្រាស់ពាក់ព័ន្ធ ដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ហើយមានចំណូលពីការលក់ទ្រព្យសម្បត្តិរដ្ឋនោះក្រោយអនុវត្តនីតិវិធីជម្រះរួច តាមរយៈការជំរុញឱ្យបង់ចំណូលចូលថវិការដ្ឋនៅគណនីទោលរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត
- ណែនាំអង្គភាពប្រើប្រាស់ដែលជម្រះទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ឱ្យតម្កល់សលាកបត្របង់ចំណូលចូលថវិការដ្ឋ ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជាក់ការថយចុះនូវទ្រព្យសម្បត្តិរដ្ឋក្នុងឆ្នាំនីមួយៗ
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់ប្រធាន **គ.ជ.ល.**។

**ប្រការ៦.-**

អនុប្រធាន អនុប្រធានប្រចាំការ និងសមាជិក នៃ **គ.ជ.ល.** ត្រូវចូលរួមប្រជុំ តាមការកោះអញ្ជើញរបស់ប្រធាន **គ.ជ.ល.**។ ក្នុងករណីអវត្តមាន ឬមានធុរៈ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ឱ្យកោះអញ្ជើញ និងដឹកនាំកិច្ចប្រជុំតាមការចាំបាច់។

អនុប្រធាន អនុប្រធានប្រចាំការ និងសមាជិក នៃលេខាធិការដ្ឋាន **គ.ជ.ល.** ត្រូវចូលរួមប្រជុំ តាមការកោះអញ្ជើញរបស់ប្រធានលេខាធិការដ្ឋាន **គ.ជ.ល.**។ ក្នុងករណីអវត្តមាន ឬមានធុរៈ ប្រធានលេខាធិការដ្ឋាន **គ.ម.ឆ.** អាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ឱ្យកោះអញ្ជើញ និងដឹកនាំកិច្ចប្រជុំតាមការចាំបាច់។

**គ.ជ.ល.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបំពេញការងាររបស់ខ្លួន។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

នាយកខុទ្ទកាល័យ ប្រធានអង្គភាពប្រើប្រាស់ថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ៤ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៧កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ១ និងប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ [illegible] ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២៤

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគលេខ៤២៩៥/២៣ ក.អ.ក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣ ស្តីពីការបង្កើតរោងចក្រផលិតកាបូប ខ្សែបូ ខ្សែពួរ ខ្សែសុវត្ថិភាព និងខ្សែក្រវាត់ការពារសុវត្ថិភាពសម្រាប់សត្វចិញ្ចឹម របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រផលិតកាបូប ខ្សែបូ ខ្សែពួរ ខ្សែសុវត្ថិភាព និងខ្សែក្រវាត់ការពារសុវត្ថិភាពសម្រាប់សត្វចិញ្ចឹម ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន ស្តេនហ្វត ថេកស្តាយ អ៊ិនដាសស្ទ្រី ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **ស្តេនហ្វត ថេកស្តាយ អ៊ិនដាសស្ទ្រី** ឯ.ក (**STANDFORD TEXTILE INDUSTRIES CO., LTD.**) តំណាងដោយលោក **ZHOU, JIADONG** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EK1865373** ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ បង្កើតរោងចក្រ**ផលិតកាបូប ខ្សែបូ ខ្សែពួរ ខ្សែសុវត្ថិភាព និងខ្សែក្រវាត់ការពារសុវត្ថិភាពសម្រាប់សត្វចិញ្ចឹម** ដែលមានទីតាំងស្ថិតនៅ**សួនឧស្សាហកម្ម វ៉ាន់ សេង (គីឡូម៉ែត្រទី២៧ ផ្លូវជាតិលេខ៣ ភូមិក្រាំងទ្រា ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ)**។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| ១- កាបូប | ១៥១២ |
| ២- ខ្សែសុវត្ថិភាព, ខ្សែបូ, ខ្សែការពារសុវត្ថិភាពសម្រាប់សត្វចញ្ចឹម | ៣២៩០ |
| ៣- ខ្សែពួរ | ១៣៩៤ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតកាបូប ខ្សែបូ ខ្សែពួរ ខ្សែសុវត្ថិភាព និងខ្សែក្រវាត់ការពារសុវត្ថិភាពសម្រាប់សត្វចិញ្ចឹម ស្កេនហ្វត ថេកស្តាយ អ៊ិនដាសស្ទ្រី ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ហេង សុខគង់**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-ខុទ្ទកាល័យរដ្ឋមន្ត្រី
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តកំពង់ស្ពឺ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ
-រដ្ឋបាលស្រុកគងពិសី
-រដ្ឋបាលឃុំព្រះនិព្វាន
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៤០០ ក.ឧ.វ.ន.ព.ក

ថ្ងៃ..................ខែ..........ឆ្នាំ..........ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.......ខែ........ឆ្នាំ២០២៤

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងសេចក្តីជូនដំណឹងលេខ៣២៤/២៤ គ.វ.ក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ សម្លៀកបំពាក់ពេទ្យ និងសម្លៀកបំពាក់សត្វចិញ្ចឹម របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ សម្លៀកបំពាក់ពេទ្យ និងសម្លៀកបំពាក់សត្វចិញ្ចឹម ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ របស់ក្រុមហ៊ុន ខេមបូ វ៉ាយថាលីធី ហ្គាម៉ិន ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **ខេមបូ វ៉ាយថាលីធី ហ្គាម៉ិន ឯ.ក** (CAMBO VITALITY GARMENT CO., LTD.) តំណាងដោយលោក FENG, DEGANG សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ EB4957743 ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ បង្កើតរោងចក្រ**កាត់ដេរសម្លៀកបំពាក់ សម្លៀកបំពាក់ពេទ្យ និងសម្លៀកបំពាក់សត្វចិញ្ចឹម** ដែលមានទីតាំងស្ថិតនៅ**ភូមិព្រៃស្ពឺ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ**។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| **សម្លៀកបំពាក់ សម្លៀកបំពាក់ពេទ្យ និងសម្លៀកបំពាក់សត្វចិញ្ចឹម** | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រកាត់ដេរសម្លៀកបំពាក់ សម្លៀកបំពាក់ពេទ្យ និងសម្លៀកបំពាក់សត្វចិញ្ចឹម ខេមបូ វ៉ាយថាលីធី ហ្វាមិន ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ. រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ហេង សុខគង់

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-ខុទ្ទកាល័យរដ្ឋមន្ត្រី
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលារាជធានីភ្នំពេញ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
-រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ
-រដ្ឋបាលសង្កាត់ចោមចៅទី២
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី